ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០១៦៩ ពណ.ជ.ក.ធ/ប្រក

# ប្រកាស

## ស្តីពី

## ការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/០១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.–**

ប្រកាសនេះ មានគោលដៅកំណត់ការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុននៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុនដោយ ប្រើពាក្យពេញ ឬជាអក្សរកាត់បាន។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.-**

នាមករណ៍របស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញលេញថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬអក្សរកាត់ថា "ឯ.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៣.-**

នាមករណ៍របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញលេញថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត" ឬអក្សរកាត់ថា "ម.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៤.-**

សហគ្រាសឯកបុគ្គលត្រូវដាក់នូវពាក្យថា "សហគ្រាសឯកបុគ្គល" នៅពីមុខនាមករណ៍នោះ។

**ប្រការ៥.-**

នាមករណ៍របស់សាខាក្រុមហ៊ុនក្នុងស្រុក គឺជានាមករណ៍របស់ក្រុមហ៊ុនដើម។ នៅពីលើ ឬនៅពីមុខនាមករណ៍របស់សាខានោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុនក្នុងស្រុក"។

នាមករណ៍របស់សាខាក្រុមហ៊ុនបរទេស គឺជានាមករណ៍របស់ក្រុមហ៊ុនដើម។ នៅពីលើ ឬនៅពីមុខនាមករណ៍របស់សាខានោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុនបរទេស"។

នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស។ នៅពីលើ ឬនៅពីមុខនាមករណ៍នេះ ត្រូវសរសេរពាក្យ "ការិយាល័យតំណាងពាណិជ្ជកម្មបរទេស ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មបរទេស"។

**ប្រការ៦.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញលេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ" ឬអក្សរកាត់ថា "ស.ទ" នៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៧.-**

នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវដាក់ពាក្យសម្គាល់ទ្រង់ទ្រាយដោយពាក្យពេញលេញថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត" ឬអក្សរកាត់ថា "ស.ក" នៅខាងចុង ឬខាងក្រោមនាមករណ៍របស់ក្រុមហ៊ុន។

**ប្រការ៨.-**

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលអនុញ្ញាតឱ្យប្រើពាក្យ ហូលឌីង (HOLDING) ឬគ្រុប (GROUP) នៅបន្ទាប់ពីឈ្មោះក្រុមហ៊ុន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. នាមករណ៍ក្រុមហ៊ុនដែលប្រើពាក្យ ហូលឌីង (HOLDING)

ក. ត្រូវមានក្រុមហ៊ុនជាបុត្រសម្ព័ន្ធយ៉ាងតិច ៣(បី)ក្រុមហ៊ុន ដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. ក្រុមហ៊ុនដើម ជាក្រុមហ៊ុនដែលត្រូវមានកម្មវត្ថុអាជីវកម្មលេខ៦៤២ (សកម្មភាពរបស់ក្រុមហ៊ុនភាគហ៊ុន) និងផ្តល់ទុនទៅឱ្យក្រុមហ៊ុនជាបុត្រសម្ព័ន្ធដើម្បីធ្វើពាណិជ្ជកម្ម។ ក្រុមហ៊ុនដើម មិនអាចធ្វើសកម្មភាពពាណិជ្ជកម្មដោយផ្ទាល់បានឡើយ

គ. ក្រុមហ៊ុនដើម ត្រូវកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥១% នៅក្នុងក្រុមហ៊ុនជាបុត្រសម្ព័ន្ធនីមួយៗ។

២. នាមករណ៍ក្រុមហ៊ុនដែលប្រើពាក្យ គ្រុប (GROUP)

ក. ត្រូវមានក្រុមហ៊ុនជាបុត្រសម្ព័ន្ធយ៉ាងតិច៣(បី)ក្រុមហ៊ុនដែលបានចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

ខ. ក្រុមហ៊ុនដើម ត្រូវកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥១% នៅក្នុងក្រុមហ៊ុនជាបុត្រសម្ព័ន្ធនីមួយៗ។

**ប្រការ៩.-**

ប្រកាសលេខ១៣៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការដាក់ពាក្យសម្គាល់ទ្រង់ទ្រាយក្រុមហ៊ុន ត្រូវទុកជានិរាករណ៍។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ១២ ខែសីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ